**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការការពារការចម្លងវីរុសកូវីដ១៩ ក្នុងអំឡុងពេលឈប់សម្រាកចំនួន ៥ថ្ងៃ ដើម្បីសងថ្ងៃឈប់សម្រាកការងារសម្រាប់បុណ្យចូលឆ្នាំប្រពៃណីជាតិ

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា យោងតាមអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ ឈប់សម្រាកការងារនៅថ្ងៃទី១៧ ទី១៨ ទី១៩ ទី២០ និងទី២១ ខែសីហា ឆ្នាំ២០២០ ដែលជាការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាការឈប់សម្រាក ដើម្បីសងថ្ងៃឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំជូត ទោស័ក ដែលត្រូវបានលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ នៅថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២០ កន្លងទៅ ដោយសារបញ្ហាកូវីដ-១៩។

ការអនុញ្ញាតឱ្យឈប់សម្រាកក្នុងរយៈពេលយូរនេះ បងប្អូនប្រជាពលរដ្ឋ នឹងអាចមានការធ្វើដំណើរទៅជួបជុំក្រុមគ្រួសារនៅស្រុកកំណើត ឬក៏អាចមានការដើរលេងកំសាន្តផងដែរ។ ក្នុងករណីនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ បន្តអនុវត្តការការពារការចម្លងវីរុសកូវីដ-១៩ ឱ្យបានខ្ជាប់ខ្ជួន ហើយក្រសួងសុខាភិបាល សូមបញ្ជាក់ជូនថា បើទោះបីជាប្រទេសកម្ពុជា មិនទាន់មានការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ក៏ដោយ ក៏វីរុសកូវីដ-១៩ នេះ នៅតែកំពុងបន្តរាតត្បាតយ៉ាងខ្លាំងនៅលើពិភពលោក និងនៅក្នុងតំបន់ ហើយការរកឃើញថ្មីៗមានវីរុសកូវីដ-១៩ លើអ្នកដំណើរជាបន្តបន្ទាប់កន្លងមកនេះ បានមកពញ្ញាក់ស្មារតីបុគ្គលគ្រប់រូប កុំឲ្យភ្លេចខ្លួន ដោយបានបង្ហាញថា ការចម្លងវីរុសកូវីដ-១៩ នៅតែមាននៅឡើយ និងនៅតែជាហានិភ័យសម្រាប់មនុស្សគ្រប់រូប ទោះជាក្នុងរូបភាពនាំចូលមកក្នុងប្រទេសក៏ដោយ ក៏យើងមិនត្រូវមានការធ្វេសប្រហែស ដោយត្រូវការពារខ្លួនតាមការណែនាំឱ្យបានត្រឹមត្រូវ ហើយមិនត្រូវមើលរំលងនូវលទ្ធភាពនៃការចម្លងរហ័សនៃវីរុសដ៏កាចសាហាវនេះ ដែលនឹងអាចកើតមានគ្រប់ពេលវេលា គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងទាំងអស់។

ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ មកបុគ្គល និងចូលក្នុងសហគមន៍ ក្រសួងសុខាភិបាល សូមធ្វើការណែនាំក្រើនរំលឹកដល់សាធារណៈជនទាំងអស់ ឱ្យប្រកាន់យកនូវការរស់នៅតាមបែបគន្លងថ្មី ដោយចេះកែប្រែទម្លាប់ និងឥរិយាបថ ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងនៅតែបន្តការការពារការចម្លងជំងឺកូវីដ-១៩នេះ ទោះជាក្នុងពេលវេលាណា ទៅទីណា និងនៅកន្លែងណាក៏ដោយ។ ដូច្នេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវ



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ចូលរួមបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវវិធានការការពារខ្លួនពីការចម្លងវីរុសកូវីដ-១៩ ដោយយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដែលមានដូចតទៅ៖

**១. ជ្រើសរើសការជួបជុំគ្រួសារ ឬដំណើរកំសាន្តប្រកបដោយសុវត្ថិភាព មិនមានការចម្លងជំងឺ**

- ជ្រើសរើសដំណើរកំសាន្តដាច់ដោយឡែក ជាលក្ខណៈគ្រួសារដែលមិនមានការជួបជុំគ្នាច្រើន ដូចជាការដើរកំសាន្តជាគ្រួសារ នៅតាមទីរមណីដ្ឋាន ឬទីកន្លែងកំសាន្ត ដែលមានបរិយាកាសល្អ មានខ្យល់ចេញចូលល្អគ្រប់គ្រាន់ មិនស្ថិតនៅក្នុងទីដែលបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើន
- ត្រូវកាត់បន្ថយឲ្យបានជាអតិបរិមា នូវការជួបជុំគ្នាដែលមានមនុស្សម្នាច្រើនដូចជា ការធ្វើដំណើរកំសាន្តប្រមូលផ្តុំគ្នាច្រើន បរិភោគអាហារជាមួយមិត្តភក្តិច្រើនខាងក្រៅផ្ទះ ការជប់លៀងទ្រង់ទ្រាយធំជាដើម
- ជៀសវាងការជួបជុំគ្នាលេងល្បែងស៊ីសង ច្រៀងរាំដែលមិនមានគម្លាតសុវត្ថិភាព ឬការជួបជុំគ្នាស៊ីផឹកគ្រឿងស្រវឹងជាដើម។ ចៀសវាងការសេពសុរាច្រើនពេក និងចៀសវាងការប្រើប្រាស់គ្រឿងញៀន ដែលធ្វើឲ្យប៉ះពាល់ដល់សុខភាព និងអាចជាកត្តាហានិភ័យខ្ពស់ក្នុងការចម្លង ឬកើតរោគផងដែរ
- ជៀសវាងការកំសាន្តនៅតាមទីកន្លែងបែបជារង្គសាល ការ៉ាអូខេ ឬ ក្លឹបកំសាន្តនានា ដែលប្រមូលផ្តុំគ្នាច្រើន ហើយដែលរាជរដ្ឋាភិបាលមិនបានអនុញ្ញាតឲ្យបើកដំណើរការនោះឡើយ

**២. ជ្រើសរើសមធ្យោបាយធ្វើដំណើរមានសុវត្ថិភាព កាត់បន្ថយជាអតិបរិមានូវការចម្លងជំងឺ**

- ជៀសវាងប្រើប្រាស់មធ្យោបាយសាធាណៈ ដែលមានផ្ទុកមនុស្សច្រើន
- បើចាំបាច់ត្រូវធ្វើដំណើរតាមមធ្យោបាយសាធារណៈ លោកអ្នកត្រូវពាក់ម៉ាស់ជានិច្ច រក្សាគម្លាតពីម្នាក់ទៅម្នាក់ឲ្យបានមួយម៉ែត្រកន្លះ និងត្រូវយកតាមខ្លួននូវទឹកអាកុល ឬទឹកដែលសំរាប់លាងដៃ
- ជៀសវាងការធ្វើដំណើរ ប្រសិនបើមានអាការៈក្តៅខ្លួន ក្អក ឬពិបាកដកដង្ហើម ឬមានបញ្ហាសុខភាព
- សម្រាប់អ្នកបើកបរ ត្រូវ៖
  - បើកបង្អួចរថយន្ត ឲ្យមានខ្យល់ចេញចូល ចៀសវាងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក
  - លើកទឹកចិត្តឲ្យអ្នកដំណើរពាក់ម៉ាស់ ឬក្រម៉ាខ្ទប់មាត់ និងច្រមុះ ដើម្បីជៀសវាងការចម្លងជាយថាហេតុនៃវីរុសផ្តាសាយផ្សេងៗ រួមទាំងវីរុសកូវីដ-១៩ ផងដែរ
  - ត្រូវសម្អាតរថយន្តជាប្រចាំដោយប្រើទឹកសាប៊ូ ជូតអាល់កុលនៅតាមធ្នាក់កៅអី និងកន្លែងដែលមនុស្សបានប៉ះពាល់
  - ម្ចាស់រថយន្តត្រូវមានទឹកអាល់កុល ឬអាល់កុលដែលលាងដៃ ឲ្យអ្នកដំណើរលាងដៃ មុនពេលឡើងលើរថយន្ត
  - ចំពោះអ្នកបើកបររថយន្ត បើមានរោគសញ្ញា ដូចជា គ្រុនក្តៅ ផ្តាសាយ ឈឺបំពង់ក ពិបាកដកដង្ហើម ជាដើម ត្រូវផ្អាកការបើកបរជាបណ្តោះអាសន្ន រួចទៅមន្ទីរពេទ្យរដ្ឋ ដើម្បីត្រួតពិនិត្យសុខភាព។ អ្នកបើកបរ មានហានិភ័យខ្ពស់ ដោយសារការជួបជាមួយមនុស្សច្រើន ដូច្នេះ ត្រូវចេះការពារខ្លួនពីការចម្លងវីរុសកូវីដ-១៩ និងមេរោគផ្សេងៗ



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## ៣. ជ្រើសរើសទីកន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៃការចម្លងជំងឺ

- ជ្រើសរើសសណ្ឋាគារ ឬផ្ទះសំណាក់ ដែលអនុវត្តវិធានការការពារ និងអនាម័យល្អ តាមការណែនាំរបស់ក្រសួងសុខាភិបាល ដូចជាមានដាក់ទឹកស្អាត និងសាប៊ូ ឬទឹកអាល់កុល ឬអាល់កុលជែល សម្រាប់លាងសំអាតដៃ និងធ្វើអនាម័យបន្ទប់ ព្រមទាំងមានការសម្អាតសម្ភារៈប្រើប្រាស់ក្នុងបន្ទប់ បានត្រឹមត្រូវ
- ប្រើប្រាស់បន្ទាប់ស្នាក់នៅ ដែលមានបង្អួចបើកបាន សម្រាប់ឱ្យមានខ្យល់ចេញចូលបានល្អ កាត់បន្ថយជាអតិប្បរិមានូវការប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬអាចប្រើកង្ហា
- ម្ចាស់សណ្ឋាគារ ឬផ្ទះសំណាក់៖
    - ត្រូវសម្អាត និងសម្លាប់មេរោគ នៅក្នុងសណ្ឋាគារ ឬផ្ទះសំណាក់របស់ខ្លួនឲ្យបានត្រឹមត្រូវ ដូចជាបន្ទប់ទឹក បន្ទប់ធំ ផ្លូវដើរ បង្កាន់ដៃជណ្តើរ ជណ្តើរយន្ត ប៊ូតុងចុចជណ្តើរយន្ត បង្កាន់ដៃទ្វារ កុងតាក់ភ្លើង និងសម្ភារប្រើប្រាស់ផ្សេងៗក្នុងបន្ទប់ភ្ញៀវជាដើម
    - ត្រូវមានគម្លាតសុវត្ថិភាពបុគ្គល នៅកន្លែងឆែកចូលយកបន្ទប់សម្រាក និងកន្លែងបង់ប្រាក់ ដោយត្រូវមានដាក់គំនូសសម្គាល់សម្រាប់តម្រង់ជួរឈរចាំឲ្យមានគម្លាតពីបុគ្គលម្នាក់ទៅម្នាក់ មួយម៉ែត្រកន្លះឡើង
    - ក្នុងបន្ទប់ទឹក ត្រូវមានសាប៊ូ ជាប់ជាប្រចាំ សម្រាប់អតិថិជន ប្រើប្រាស់សម្រាប់លាងដៃ ក្នុងកំឡុងពេលស្នាក់នៅរបស់អតិថិជន
    - ត្រូវតែអនុវត្តវិធានការការពារនៅទីតាំងរបស់ខ្លួន ដើម្បីចៀសវាងការចម្លងវីរុសកូវីដ-១៩ ឬចម្លងជំងឺ ពីអតិថិជនមួយទៅអតិថិជនម្នាក់ ឬច្រើននាក់

## ៤. ជ្រើសរើសការទទួលទានអាហារ ប្រកបដោយសុវត្ថិភាព មិនបង្កការចម្លងជំងឺ

- រក្សាអនាម័យចំណីអាហារ ដូចជាបរិភោគអាហារឆ្អិនល្អ ទុកដាក់អាហារឆៅ និងឆ្អិនដាច់ដោយឡែកពីគ្នា ទុកដាក់អាហារក្នុងសីតុណ្ហភាពសុវត្ថិភាព និងប្រើប្រាស់ទឹកស្អាត និងវត្ថុធាតុដើមល្អ សម្រាប់ចម្អិនអាហារជាដើម
- ម្ចាស់ និងបុគ្គលិកបម្រើការនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ត្រូវធ្វើអនាម័យខ្លួនឯង លាងសំអាតដៃ និងអនាម័យផ្លូវដង្ហើមជាទៀងទាត់ ដូចជាពាក់ម៉ាស់ឱ្យបានត្រឹមត្រូវជានិច្ច ក្នុងពេលបម្រើអតិថិជន និងក្នុងពេលចាំបាច់
- ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ត្រូវរៀបចំឲ្យមានកន្លែងលាងដៃ និងលើកទឹកចិត្តអតិថិជនចូលមកកន្លែងរបស់ខ្លួន ឱ្យលាងដៃរបស់ពួកគាត់ ជាមួយសាប៊ូ និងទឹកស្អាត ឬជាមួយទឹកអាល់កុល ឬអាល់កុលជែលសម្រាប់លាងដៃ ដែលមានដាក់នៅតាមច្រកចូលទៅកាន់កន្លែង
- រៀបចំតុ និងកៅអីអង្គុយ ព្រមទាំងត្រូវណែនាំភ្ញៀវឲ្យរក្សាគម្លាតសុវត្ថិភាពរវាងភ្ញៀវម្នាក់ទៅភ្ញៀវម្នាក់ទៀត ចម្ងាយមួយម៉ែត្រកន្លះឡើង
- ចំពោះភោជនីយដ្ឋានដែលមានអាហារប៊ូហ្វេ ត្រូវប្តូរឧបករណ៍ចាប់ម្ហូបឱ្យបានញឹកញាប់ និងត្រូវសម្អាតទីកន្លែងដាក់ម្ហូបជានិច្ច បន្ទាប់ពីភ្ញៀវបានប្រើរួច។ ជូតសម្អាតម៉ាស៊ីនឆុងកាហ្វេ និងម៉ាស៊ីនភេសជ្ជៈញឹកញាប់ បន្ទាប់ពីភ្ញៀវម្នាក់ៗប្រើរួច
- អ្នកបម្រើក្នុងភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ទាំងអស់ ត្រូវតែពាក់ម៉ាស់ជានិច្ច និងរាល់ពេលបម្រើអតិថិជន



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- ត្រូវតែសំអាតតុ និងកៅអី ដែលភ្ញៀវបានក្រោកចេញ ឲ្យបានត្រឹមត្រូវ ដោយប្រើអាល់កុល មុននឹងអនុញ្ញាតឲ្យភ្ញៀវបន្ទាប់ចូលអង្គុយ
- ក្នុងបន្ទប់ទឹក ត្រូវមានសាប៊ូ ជាប់ជាប្រចាំ សម្រាប់អតិថិជន ប្រើប្រាស់សម្រាប់លាងដៃ ពេលប្រើប្រាស់បង្គន់ មុនពេល និងក្រោយពេលបរិភោគអាហាររួច
- សម្ភារៈប្រើប្រាស់ ចាន ស្លាបព្រា កែវទឹកកម្រាលតុ ឬកន្សែង និងវត្ថុប្រើប្រាស់ផ្សេងៗ ត្រូវតែលាងសំអាតឲ្យបានត្រឹមត្រូវ មុនដាក់ឲ្យអតិថិជនប្រើប្រាស់
- មិនត្រូវចូលទៅជួបជុំគ្នា ឬនាំគ្នាបរិភោគអាហារជុំគ្នា នៅទីកន្លែងដែលមិនមានសុវត្ថិភាព និងដែលអាចជាកន្លែងមានការងាយស្រួលក្នុងការចម្លងវីរុសកូវីដ-១៩ ឬចម្លងរោគផ្សេងៗ ដូចជាកន្លែងដែលមានការស្រែកហោរកញ្ជ្រាវ ឬបន្ទប់ដែលបិទជិតងងឹតៗ មិនមានខ្យល់ចេញចូលបានល្អ ជាដើម

## ៥. បុគ្គលម្នាក់ៗ ត្រូវរក្សាអនាម័យជានិច្ច

- ត្រូវលាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ទឹកអាល់កុល ឬទឹកអាល់កុលជែល ឲ្យបានញឹកញាប់ និងជាប្រចាំ
- ត្រូវខ្ទប់មាត់ និងច្រមុះពេលក្អក កណ្តាស់ ដោយប្រើម៉ាស់ ក្រម៉ា កន្សែង ឬក្រដាសអនាម័យ រួចខ្ចប់បោះចោលក្នុងធុងសម្រាមបិទជិត
- ពាក់ម៉ាស់ នៅពេលចាំបាច់
- ត្រូវជៀសវាង ការខាកស្តោះពាសវាលពាសកាល

## ៦. ត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល

- ត្រូវរក្សាគម្លាតសុវត្ថិភាពពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត យ៉ាងតិចមួយម៉ែត្រកន្លះ នៅពេលឈរ អង្គុយ ឈររង់ចាំ ឈរជជែកគ្នា ឬនៅទីកន្លែងផ្សេងៗ ដូចជាកន្លែងធ្វើការ កន្លែងសាធារណៈ ភោជនីយដ្ឋាន អាហារដ្ឋាន ទីកន្លែងកំសាន្តលំហែកាយ ឬទីកន្លែងទេសចរនានា
- អ្នកដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺ ដូចជាជនចាស់ជរា ជនដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ និងកុមារតូចៗជាដើម មិនត្រូវចូលរួមដំណើរ ជួបប្រជុំគ្នាច្រើន ឬបើមានការចាំបាច់បំផុតនោះ ត្រូវតែមានការអនុវត្តន៍កិច្ចការពារខ្លួនឲ្យបានល្អ និងរក្សាគម្លាតពីគ្នា ព្រមទាំងមានអ្នកជួយមើលការខុសត្រូវឲ្យបានត្រឹមត្រូវ ព្រមទាំងអនុវត្តវិធានការដូចបានជម្រាបជូនខាងលើនេះ។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ ហើយក្រសួង ក៏សូមអំពាវនាវដល់សាធារណជនទាំងអស់សូមចូលរួមអនុវត្តតាមការណែនាំខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីចូលរួមចំណែកកាត់ផ្តាច់ការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ និងកុំឲ្យមានការចម្លងទៅសហគមន៍។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋ មានបញ្ហាសុខភាព ឬមានជំងឺ ឬសង្ស័យថាមានការឆ្លងជំងឺ សូមប្រញាប់ទៅស្វែងរកការពិនិត្យព្យាបាលនៅតាមមន្ទីរពេទ្យរដ្ឋ ឬទំនាក់ទំនងតាមលេខផ្តល់ជូនខាងក្រោមនេះ។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រ ហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាច



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម មានបញ្ហាសុខភាព សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ក្រសួងសុខាភិបាល សូមជូនពរដល់បងប្អូនសាធារណជនទាំងអស់ ទទួលបាននូវសុខភាពល្អ ជៀសផុតពីការចម្លងវីរុសកូវីដ-១៩ សម្រាប់បុគ្គលផ្ទាល់ សម្រាប់ក្រុមគ្រួសារ និងសម្រាប់សហគមន៍ មិនមានការចម្លងវីរុសកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង